# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ...២១៦...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មការមូលបត្រកម្ពុជា

---

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៨ ស្តីពីការការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៨/៩២៨ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងអគ្គនាយក អគ្គនាយករង នៃគណៈកម្មការមូលបត្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ស ម្រេ ច

មាត្រា ១.- ត្រូវបានតែងតាំងសមាសភាពគណៈកម្មការមូលបត្រកម្ពុជា ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាប្រធាន |
| ២. លោកជំទាវ **ខួន សុខា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៣. លោកជំទាវ **នាង ច័ន្ទធារណា** | អគ្គទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | ជាសមាជិក |
| ៤. លោកជំទាវ **តឹកវ៉េត តំរេខ** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ជាសមាជិក |

| | | | |
|---|---|---|---|
| ៥. ឯកឧត្តម | **ភើត រិទ្ធ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ជាសមាជិក |
| ៦. ឯកឧត្តម | **ភីម រ័ត្នវិសិដ្ឋ** | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៧. ឯកឧត្តម | **ម៉ិញ ចានកុសល** | អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា | ជាសមាជិក |
| ៨. លោកបណ្ឌិត | **សំ ឃន្ធី** | អ្នកជំនាញវិជ្ជាជីវៈឯកជន | ជាសមាជិក |
| ៩. លោកបណ្ឌិត | **សំ សុខុម** | អ្នកជំនាញវិជ្ជាជីវៈឯកជន | ជាសមាជិក |

**មាត្រា ២.-** អនុក្រឹត្យលេខ ៣៩៦ អនក្រ.តត ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៩ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង គ្រប់ប្រធានស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គណៈកម្មការមូលបត្រកម្ពុជា
- ដូចមាត្រា ៣ " ដើម្បីអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ